# វិធីសមាទាននិច្ចសីល

ពុទ្ធសាសនិកជនដែលបានដល់ព្រះត្រៃសរណគមន៍ បានឡើងនាមបញ្ញត្តិជាអុបាសក រឺអុបាសិកាហើយ កាលបើនឹងសមាទាននិច្ចសីល គឺសីល៥ ជាបច្ចេកសមាទាន អំពីបុគ្គលដទៃ គឺភិក្ខុ រឺសាមណេរនោះគ ប្បីស្វែគ្រនមស្សការថ្វាបង្គំលើកដល់ព្រះ រតនត្រៃដោយសង្ខេបជាមុន រួចហើយត្រូវសូមនូវនិច្ចសីលព្រម ទាំងព្រះត្រៃសរណ គមន៍ចំពោះភិក្ខុរឺសាមណេរដែលខ្លួននឹងសូមសមាទាននោះថា៖

អុកាស មយំ ភន្តេ វិសុំវិសុំ រក្ខនត្ថាយ តិសរណេន សហបញ្ច សីលានិ យាចាមិ។

ទុតិយម្បិ មយំ ភន្តេ វិសុំវិសុំ រក្ខនត្ថាយ តិសរណេន សហបញ្ច សីលានិ យាចាមិ

តតិយម្បិ មយំ ភន្តេ វិសុំវិសុំ រក្ខនត្ថាយ តិសរណេន សហបញ្ច សីលានិ យាចាមិ។

បើម្នាក់អែងសូមប្តូរ មយំ, យាចាមិ ថា អហំ, យាចាម វិញ

ប្រែថា សូមគោរព បពិតព្រះករុណាដ៏ចំរើន ខ្ញុំព្រះករុណាទាំងឡាយសូមនិច្ចសីលទាំងឡាយ៥មួយអន្លើ ដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍រក្សាផ្សេងៗគ្នា បពិតព្រះករុណាដ៏ចំរើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះ អោយនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ។

បពិតព្រះករុណាដ៏ចំរើនខ្ញុំព្រះករុណាទាំងឡាយ សូមនិច្ចសីលទាំងឡាយ៥មួយអន្លើ ដោយព្រះត្រៃសរណ គមន៍ដើម្បីប្រយោជន៍រក្សាផ្សេងៗ គ្នាបពិតព្រះករុណាដ៏ចំរើនសូម ព្រះករុណាមេត្តា ធ្វើនូវសេចក្តីអនុ គ្រោះអោយនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ជាគំរប់ពីរដងផង។ បពិតព្រះករុណាដ៏ចំរើនខ្ញុំព្រះករុណា ទាំង ឡាយ សូមនិច្ចសីលទាំងឡាយ៥មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍រក្សាផ្សេងៗ គ្នា បពិតព្រះករុណាដ៏ចំរើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះអោយនូវសីលដល់ខ្ញុំព្រះករុណា ទាំងឡាយជាគំរប់បីដងផង

បើម្នាក់អែងប្តូរត្រង់ខ្ញុំព្រះករុណាទាំងឡាយថា ខ្ញុំព្រះករុណាវិញ

លោកសូត្រ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស បីដង

ប្រែថា រីកិរិយាថ្វាយបង្គំនៃ ខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ។

ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក

ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ជាទីពឹងទីរលឹក

សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីពឹងទីរលឹក

ទុតិយម្បិ (ពុទ្ធំ, ធម្មំ, សង្ឃំ) សរណំគច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវ

( ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ ) ជា ទីពឹងទីរលឹក ជាគំរប់ពីរដងផង។

តតិយម្បិ (ពុទ្ធំ ,ធម្មំ, សង្ឃំ) សរណំគច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវ

( ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ ) ជាទីពឹងទីរលឹក ជាគំរប់បីដងផង។

តិសរណគ្គហណំ បរិបុណ្ណំ កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍បរិបូណ៌ តែប៉ុណ្ណេះ។

អ្នកសមាទានត្រូវទទួលថា «អាម ភន្តេ» ករុណាលោកម្ចាស់។ ហើយលោកអោយនិច្ចសីលជាបច្ចេកសមាទានថា

បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិត អោយធ្លាក់ចុះក្នុងគន្លង គឺសំលាប់សត្វ។

អទិន្នាទានា វេរមណី សិក្ខាបទំសមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានអោយដោយ កាយរឺដោយវាចា។

កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាន នូវសិក្ខាបទ គឺចេតនាជា

ហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។

មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក។

សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាតាំងនៃ សេចក្តីប្រមាទគឺផឹក នូវទឹកស្រវឹងគឺសុរានិងមេរ័យ។

រួចហើយលោកអ្នកអោយសីល លោកពោលដាស់តឿនក្រើនរំលឹកថា

ឥមានិបញ្ច សិក្ខាបទានិ សាធុកំ កត្វាអប្បមាទេន និច្ចកាលំ សម្មា រក្ខិតព្វំ

ប្រែថា អ្នក(អ្នកទាំងឡាយ)គប្បីធ្វើនូវសិក្ខាបទទាំងឡាយ៥នេះអោយប្រពៃ ត្រូវរក្សាអោយល្អអស់កាលជានិច្ចដោយសេចក្តីមិនប្រមាទ គឺថាកុំធ្វើប្រហែសឡើយ។

អ្នកសមាទានត្រូវទទួលថា អាម ភន្តេ ប្រែថាករុណាលោកម្ចាស់។

ហើយលោក សំដែងអានិសង្សសីលអោយស្តាប់តទៅទៀតថាៈ

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា សីលេន និព្វុតឹ យន្តិ តស្មា សីលំវិសោធយេ

ប្រែថា សត្វទាំងឡាយទៅកាន់ស្ថានសួគ៌បានក៏ព្រោះសីល សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈក៏ព្រោះសីល សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខគឺព្រះនិព្វាន ក៏ព្រោះសីល ព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជំរះនូវសីលអោយបរិសុទ្ធ កុំអោយសៅហ្មង។

អ្នកសមាទានត្រូវទទួលថា សាធុប្រពៃហើយ។

វិធីសមាទានសីលជាបច្ចេកសមាទានចប់តែប៉ុណ្ណេះ។

## វិធីសមាទានឧបោសថសីល

ឧបាសកឧបាសិកាជាអ្នករក្សានូវឧបោសថសីល កាលបើដល់ថ្ងៃជិតនឹងរក្សាឧបោសថសីល គឺថ្ងៃមុន១ថ្ងៃដែលកំណត់ថាព្រឹកឡើយនឹងរក្សានូវឧបោសថសីលនោះ គប្បីចាត់ចែងការងារដែលគួរនឹងចាត់ចែងមាន

វិធីចាត់ចែងនូវអាហារជាដើមដែល ជាការងារ គឺខ្លួននឹងត្រូវធ្វើវិនឹងត្រូវប្រើអោយគេធ្វើក្នុងថ្ងៃស្អែក គឺក្នុងថ្ងៃអុបោសថកាល អោយហើយក្នុងថ្ងៃនោះមុន តែកុំចាត់ចែងការងារដែលមិនប្រកបដោយធម៌ ដែលជាការងារ គឺខ្លួនជាអុបាសកអុបាសិកាមិនគួរនឹងចាត់ចែងនោះឡើយ លុះដល់ព្រឹកឡើងជាថ្ងៃអុបោសថកាល ត្រូវរក្សានូវអុបោសថសីល គប្បីភ្ញាក់ឡើងអំពីព្រលឹម ហើយខ្ពុរមាត់ជំរះធ្មេញអោយស្អាតរួចហើយបើបានសមាទាននូវអុបោសថក្នុងវេលានោះក៏ជាការប្រពៃ បើឃើញថានឹងសមាទានពីព្រលឹម នោះមិនទាន់ទេ ក៏គប្បីកំណត់នូវអុបោសថកាល គឺកាលជាទីរក្សានូវអុបោសថសីលក្នុង១ថ្ងៃ១យប់នោះដោយបញ្ចេញវាចាអធិដ្ឋានថា៖

អជ្ជ អុបោសថោ អិមញ្ច រត្តឹ អិមញ្ច ទិវសំ អុបោសថិកោ (បើ ស្ត្រីថាអុបោសថិកា) ភវិស្សាមិ

ប្រែថា ថ្ងៃនេះជាថ្ងៃត្រូវរក្សានូវអុបោសថសីល ខ្លួនខ្ញុំនឹងជាអ្នករក្សានូវអុបោសថសីលអស់ថ្ងៃនេះ និងយប់នេះ។

បើមិនចេះបាលី នឹងអធិដ្ឋានតាមភាសារបស់ខ្លួន ក៏គួរសច្ចាដោយពិត លុះអធិដ្ឋាន កំណត់កាលដូច្នេះរួចហើយត្រូវតាំងវិរតិចេតនាវៀរចាកសីលភេទ គឺហេតុផលជា ទីទំលាយនូវសីលនោះៗ អោយគ្រប់សិក្ខាបទទាំង៨ កាលបើអធិដ្ឋានដូច្នេះហើយ តអំពីពេលនោះមក ក៏គប្បីសមាទាននូវអុបោសថសីលអំពីបុគ្គលដទៃមានភិក្ខុជាដើម តាមកាលដ៏គួរចុះ បើទុកជាដល់ពេលព្រះអាទិត្យរះខ្ពស់ឡើងប្រមាណពេញពន្លឺធំទើបសមាទានក្តី ក៏ឈ្មោះថាបានសមាទានដោយប្រពៃ ឈ្មោះថាបានរក្សានូវអុបោសថសីលពេញកាលកំណត់១ថ្ងៃ១យប់ដោយបរិបូរណ៍ ព្រោះអ្នកសមាទានបាន ធ្វើនូវអុបោសថកាលមិនអោយខ្វះខាត ទាំងវិរតិចេតនាសោតក៏កើតភ្លាមបរិបូណ៌ ក្នុងសន្តាន នឹងបានផលានិសង្សច្រើន។

កាលបើអុបាសកអុបាសិកា នឹងសមាទាននូវអុបោសថសីល ប្រកបព្រមដោយអង្គ ៨ ជាបច្ចេកសមាទានអំពីបុគ្គលដទៃគឺ ភិក្ខុវិសាមណេរនោះគប្បីសូត្រនមស្សការ ថ្វាយរលឹកដល់គុណព្រះរតនត្រៃ ដោយសង្ខេបជាមុនរួចហើយ ត្រូវសូមអុបោសថ សីលព្រមទាំងព្រះត្រៃសរណគមន៍ពីភិក្ខុវិសាមណេរដែលខ្លួននឹងសមាទាននោះថា៖

អុកាស មយំ ភន្តេ វិសុំវិសុំ រក្ខន្ថាយ តិ សរណេន សហ អដ្ឋ សីលានិ យាចាមិ។

ទុតិយម្បិ មយំ ភន្តេ វិសុំវិសុំ រក្ខន្ថាយ តិសរ ណេន សហ អដ្ឋ សីលានិ យាចាមិ

តតិយម្បិ មយំ ភន្តេ វិសុំវិសុំ រក្ខន្ថាយ តិសរ ណេន សហ អដ្ឋ សីលានិ យាចាមិ

បើម្នាក់អែងសូមប្តូរ មយំ,យាចាម ថា អហំ, យាចាម វិញ

ប្រែថា សូមគោរព បពិតព្រះករុណាដ៏ចំរើនខ្ញុំព្រះករុណាទាំងឡាយ សូមសីលទាំង ឡាយ៨មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍រក្សាផ្សេងៗគ្នា បពិត ព្រះករុណាដ៏ចំរើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះអោយ នូវសីលដល់ ខ្ញុំព្រះករុណាទាំងឡាយ។

បពិតព្រះករុណាដ៏ចំរើនខ្ញុំព្រះករុណាទាំងឡាយ សូមលីលទាំងឡាយ៨មួយអន្លើ ដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍រក្សាផ្សេងៗគ្នា បពិតព្រះករុណាដ៏ចំរើនសូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះអោយនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយជាគំរប់ពីរដងផង។

បពិតព្រះករុណាដ៏ចំរើន ខ្ញុំព្រះករុណាទាំងឡាយសូម លីលទាំងឡាយ ៨មួយអន្លើ ដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍រក្សាផ្សេងៗគ្នា បពិតព្រះករុណាដ៏ចំរើនសូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះអោយនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយជាគំរប់បីដងផង។

បើម្នាក់អែងប្តូរត្រង់ខ្ញុំព្រះករុណាទាំងឡាយថា ខ្ញុំព្រះករុណាវិញ

រឺនឹងសូមថា៖

អុកាស មយំ ភន្តេ វិសុំវិសុំ រក្ខន្ថាយ តិសរណេនសហ អដ្ឋង្គសមនាគំ អុបោសថំ យាចាមិ។

ទុតិយម្បិ មយំ ភន្តេ វិសុំវិសុំ រក្ខន្ថាយ តិសរណេនសហ អដ្ឋង្គសមនាគំ អុបោសថំ យាចាមិ

តតិយម្បិ មយំ ភន្តេ វិសុំវិសុំ រក្ខន្ថាយ តិសរណេនសហ អដ្ឋង្គសមនាគំ អុបោសថំ យាចាមិ

បើម្នាក់អែងសូមប្តូរ មយំ,យាចាម ថា អហំ, យាចាម វិញ

ប្រែថា សូមគោរព បពិតព្រះករុណាដ៏ចំរើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវអុបោ សថលីលប្រកបព្រមដោយអង្គ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា បពិតព្រះករុណា

ដ៏ចំរើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះអោយនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ។

បពិតព្រះករុណាដ៏ចំរើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវអុបោសថលីលប្រកបព្រម ដោយអង្គ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍រក្សាផ្សេងៗគ្នា បពិតព្រះករុណាដ៏ចំរើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះ អោយនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ជាគំរប់ពីរដងផង។

បពិតព្រះករុណាដ៏ចំរើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវអុបោសថលីលប្រកបព្រម ដោយអង្គ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ដើម្បីប្រយោជន៍ រក្សាផ្សេងៗគ្នា បពិតព្រះករុណាដ៏ចំរើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះអោយនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយជាគំរប់បីដងផង។

បពិតព្រះករុណាដ៏ចំរើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះអោយនូវសីលដល់ខ្ញុំព្រះ (ករុណា/ករុណាទាំងឡាយ)។

សូមដូច្នេះក៏បាន តាមសេចក្តីពេញចិត្តរបស់អ្នកសូម សេចក្តីអធិប្បាយអំពីអ្នកសូមតែម្នាក់ និងច្រើននាក់នោះ ដូចគ្នានឹងវិធីសូមនិច្ចសីលដូចខាងដើម។

រួចហើយលោកអ្នកអោយសីលលោកតាំង នមោ ៣ចប់ ហើយលោកអោយព្រះត្រៃសរណគមន៍ អ្នកសមាទានត្រូវទទួលថាតាមលោកដូចវិធីសមាទាននិច្ចសីលខាងដើម រួចហើយលោកអោយនូវអុបោសថសីលជាបច្ចេកសមាទានថា៖

បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមា ទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វ មានជីវិតអោយធ្លាក់ចុះក្នុងគន្លង គឺសំលាប់សត្វ។

អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបាន អោយដោយ កាយរឺដោយវាចា។

អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ

វៀរចាកកិរិយាប្រព្រឹត្តធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម។

មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុ
វៀរចាកកិរិយាពោលនូវពាក្យកុហក។

សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូម សមាទាននូវសិក្ខាបទគឺ
ចេតនាជាហេតុវៀរចាកហេតុជាទីតាំង នៃសេចក្តីប្រមាទគឺ ផឹកនូវទឹកស្រវឹងគឺសុរា និងមេរ័យ។

វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេ
តុវៀរចាកកិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស។

នច្ចគីតវាទិតវិសូកទស្សន មាលាគន្ធវិលេបនធារណមណ្ឌន វិភូស នដ្ឋានា វេរមណី សិក្ខាបទំ សមាទិយា
មិ ខ្ញុំព្រះករុណាសូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុ វៀរចាកកិរិយារាំ និងច្រៀង និងមើលនូវ
ល្បែងដែលជាសត្រូវដល់កុសលធម៌ និងកិរិយាទ្រទ្រង់ និងប្រដាប់ និងតាក់តែងស្អិតស្អាងរាងកាយដោ
យផ្កាកំរង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ។

អុច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេត
នាជាហេតុវៀរចាកទីសេនាសនៈ ដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ។

រួចអ្នកសមាទានសូត្រកំណត់អុបោសថកាលថាៈ
អិមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញាត្តំ អុបោថំ អិមញ្ចា រត្តឹ អិមញ្ញា ទិវិសំ សម្មទេវ អភិ រក្ខិតុំ សមាទិយាមិ

ខ្ញុំព្រះករុណាសូមសមាទាននូវអុបោសថសីល ដ៏ប្រកបព្រមដោយអង្គ៨ ដែលព្រះ សម្មាសម្ពុទ្ធជាម្ចាស់ទ្រ
ង់ត្រាស់បញ្ញាត្តិទុកហើយនេះ ដើម្បីនឹងរក្សាអោយបរិបូរណ៍ ប្រពៃអស់កាលកំណត់ថ្ងៃនេះនិងយប់នេះ
សូមកុសលចូរជាអុបនិស្ស័យធ្វើអោយ ច្បាស់នូវព្រះនិព្វាន អែដ៏អានាគតទៅមុខនោះហោង។

រួចហើយលោកអ្នកអោយសីល លោកពោលដាស់តឿនក្រើនរំលឹកថា

អិមានិ អដ្ឋ សិក្ខាបទានិ សាធុកំ អុបោសថសីលវសេន អិ

មញ្ចារត្តឹ អិមញ្ចា ទិវសំ សាធុកំ កត្វាអប្បមាទេន សម្មារក្ខិតព្វំ

ប្រែថា អ្នកទាំងឡាយគប្បីធ្វើនូវសិក្ខាបទទាំឡាយ៨នេះអោយប្រពៃ ត្រូវរក្សាអោយល្អអស់កាលត្រឹម ១យប់១ថ្ងៃនេះដោយសេចក្តីមិនប្រមាទ គឺថាកុំធ្វើប្រហែសឡើយ។

អ្នកសមាទានត្រូវទទួលថា អាម ភន្តេ ប្រែថា ករុណាលោកម្ចាស់។

ហើយលោក សំដែងអានិសង្សសីលអោយស្តាប់តទៅទៀតថា៖

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទាសីលេន និព្វុតឹ យន្តិ តស្មា សីលំវិសោធយេ

ប្រែថា សត្វទាំងឡាយទៅកាន់ស្ថានសួគ៌បានក៏ព្រោះសីល សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈក៏ ព្រោះសីល សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វាន ក៏ព្រោះសីល ព្រោះហេតុនោះ បុគ្គលជា សប្បុរស គប្បីជំរះនូវសីលអោយបរិសុទ្ធ កុំអោយសៅហ្មង។

អ្នកសមាទានត្រូវទទួលថា សាធុ ប្រពៃហើយ។

វិធីសមាទានអុបោសថសីលជាបច្ចេកសមាទានចប់តែប៉ុណ្ណេះ។